**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

# សេចក្តីប្រកាសព័ត៌មានរួម

## ស្តីពីពិធីចុះហត្ថលេខា

## លើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង

## រវាងរាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន

នៅព្រឹកថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង លោក Yuichi SUGANO ប្រធានតំណាង JICA ប្រចាំនៅកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង សម្រាប់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធបង្ហូរទឹកកខ្វក់ក្នុងរាជធានីភ្នំពេញ (The Project for Sewerage System Development in Phnom Penh) ដែលមានទឹកប្រាក់ចំនួន **២ ៧៧៧** លានយ៉េន (ប្រមាណជា **២៧** លានដុល្លារអាមេរិក)។

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធបង្ហូរទឹកកខ្វក់ក្នុងរាជធានីភ្នំពេញនេះ មានទិសដៅចម្រោះទឹកកខ្វក់មុនពេលបង្ហូរចូលទន្លេ តាមរយៈការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់មួយ កន្លែងនៅបឹងជើងឯក ក្នុងសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ និងបំពង់បង្ហូរទឹកកខ្វក់ដែលមានប្រវែង ២ ០០០ ម៉ែត្រ មានមុខកាត់ ៥០០ ម.ម តភ្ជាប់ពីស្ថានីយ៍បូមបឹងត្របែក។ រោងចក្រប្រព្រឹត្តកម្មនេះ មានសមត្ថភាពចម្រោះទឹកកខ្វក់បាន ៥ ០០០ ម៉ែត្រគូប ក្នុងមួយថ្ងៃ។ ការសាងសង់នឹងត្រូវចាប់ផ្តើមនៅចុងឆ្នាំ២០២០ ដែលមានរយៈពេលប្រមាណ ៣២ខែ។ បន្ថែមពីលើការសាងសង់គម្រោងក៏នឹងផ្តល់ជំនួយបច្ចេកទេសសម្រាប់ពង្រឹងសមត្ថភាពមន្ត្រីក្នុងការគ្រប់គ្រងរោងចក្រដំណើរការ និងហិរញ្ញវត្ថុផងដែរ។ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធបង្ហូរទឹកកខ្វក់ក្នុងរាជធានីភ្នំពេញនេះ ជាគម្រោងបំពេញបន្ថែមឲ្យគម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយលូក្នុងរាជធានីភ្នំពេញ ជំហានទី១ ទី២ ទី៣ និងទី៤ ដែលត្រូវបានសាងសង់ដោយហិរញ្ញប្បទានឥតសំណងរបស់ប្រទេសជប៉ុនផងដែរ។ គម្រោងនេះ នឹងចូលរួមចំណែកដល់កិច្ច

ខិតខំប្រឹងប្រែងរបស់សាលារាជធានីភ្នំពេញ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា ដែលបានឆ្លើយតបយ៉ាងជាក់ច្បាស់ ទៅនឹងសេចក្តីត្រូវការជាអាទិភាព ក្នុងការអភិវឌ្ឍប្រព័ន្ធចម្រោះទឹកកខ្វក់ ដែលនាំមកនូវការការពារ និងលើកម្ពស់គុណភាពទឹក និងអនាម័យបរិស្ថាន ស្របទៅនឹង**មុំទី១ នៃចតុកោណទី៤ ដូចមានចែងក្នុង ឯកសារយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។**

កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងដែលនឹងត្រូវចុះហត្ថលេខានេះ គឺជាឯកសារគតិយុត្តិមួយទៀត បន្ទាប់ពីលិខិតប្តូរសារដែលទើបត្រូវបានចុះហត្ថលេខា កាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ ២០១៩ កន្លងទៅ រវាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា និងស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា ដែលអាចនាំឲ្យឈានទៅដល់ការអនុវត្តនីតិវិធីបន្តបន្ទាប់ទៀតសម្រាប់ការអនុវត្តគម្រោងជាក់ស្តែង។

ជារួម ហិរញ្ញប្បទានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ (Japanese ODA) ពីប្រទេសជប៉ុន និងប្រជាជនជប៉ុន ឬនិយាយឲ្យចំទៅថា “អ្នកបង់ពន្ធជប៉ុន” ចាប់ពីដំណើរការ កសាងសន្តិភាព និងការបង្រួបបង្រួមជាតិនៅកម្ពុជា រហូតមកដល់បច្ចុប្បន្ន មានចំនួនសរុបប្រមាណជាង ៥ ០០០ លានដុល្លារអាមេរិក ក្នុងនោះមានហិរញ្ញប្បទានឥតសំណងប្រមាណជាង ៣ ៥០០ លានដុល្លារអាមេរិក។

*******************